# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ សំនួរនិងចម្លើយស្តីអំពីសិទ្ធិមនុស្ស (តមកពីលេខមុន)

www.hoksavann.org

ថ្ងៃទី២២ វិច្ឆិកា ២០១២



១៨- សំនួរ ៖ តើសិទ្ធិសញ្ញាសន្តិភាពខ្មែរនិយាយថាម៉េចខ្លះអំពីសិទ្ធិមនុស្ស ?

ចម្លើយ ៖ អ្នកដឹកនាំបក្សនយោបាយទាំងអស់នៃឧត្តមក្រុមប្រឹក្សាជាតិ ដែលបានចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិភាពនៅក្រុងប៉ារីសបានសន្យាជាឧឡារិកថា ពលរដ្ឋគ្រប់រូបនៅក្នុងស្រុកខ្មែរ ព្រមទាំងជនភៀសខ្លួនខ្មែរទាំងអស់ នឹងត្រូវមានសិទ្ធិសព្វបែបយ៉ាង ដូចមានចែងយ៉ាងពិស្តារនៅក្នុងសេចក្តីថ្លែងការណ៍ជាសកលស្តីអំពីសិទ្ធិមនុស្ស ។

ហេតុនេះសូមបងប្អូនខ្មែរគ្រប់រូបយកចិត្តទុកដាក់អានច្បាប់សិទ្ធិមនុស្ស «សេចក្តីថ្លែងការណ៍ជាសកលស្តីអំពីសិទ្ធិមនុស្ស» នេះឲ្យបានល្អិតល្អន់ ។

អ្នកដឹកនាំបក្សនយោបាយខ្មែរថែមទាំងបានសន្យាថា នឹងគោរពប្រតិបត្តិតាមកំរងបទវិន័យសំរាប់ការប្រព្រឹត្ត ដែលមានចែងនៅក្នុងសេចក្តីថ្លែងការណ៍ និងសន្ធិសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិមនុស្ស ។ ប្រសិនបើពលរដ្ឋខ្មែរទាំងអស់, អង្គការសហប្រជាជាតិ ព្រមទាំងប្រទេសទាំងឡាយដែលបានចុះហត្ថលេខាលើសន្ធិសញ្ញាអន្តរជាតិនៅប៉ារីស មិនខិតខំធ្វើយ៉ាងណាឲ្យអ្នកកាន់រដ្ឋអំណាចខ្មែរទាំងអស់គោរពតាមពាក្យគេសន្យាទេនោះ សន្ធិសញ្ញាសន្តិភាពនោះនឹងក្លាយទៅជាគ្មានន័យ ។

ការចុះហត្ថលេខាយល់ព្រមនេះមានន័យថា មេដឹកនាំខ្មែរទាំងអស់សន្យាថា នឹងគាំទ្រពលរដ្ឋខ្មែរឲ្យមានសិទ្ធិពេញទីក្នុងការពង្រឹងនិងពង្រីកសកម្មភាពសិទ្ធិមនុស្ស ព្រមទាំងឲ្យមានការគោរពសិទ្ធិនេះដ៏ត្រឹមត្រូវ ។ ហើយពួកគេសន្យាថា ប្រកាន់យកវិធានការដ៏ស័ក្តិសិទ្ធិនានាដើម្បីខាឃាំងកុំឲ្យការរំលោភជិះជាន់, ការប្រព្រឹត្តដ៏សាហាវឃោរឃៅ និងគោលនយោបាយដ៏អាក្រក់ហួសហេតុ ពីសម័យចាស់វិលត្រឡប់វិញបាន ។

អ្នកដឹកនាំខ្មែរបានសន្យាថា នឹងអនុញ្ញាតឲ្យបងប្អូនខ្មែរភៀសខ្លួនគ្រប់ប្រភេទ វិលត្រឡប់ទៅរស់នៅក្នុងភូមិស្រុកវិញ ដោយសុខសាន្ត ប្រកបដោយសន្តិសុខ និងសេចក្តីថ្លៃថ្នូរដូចពលរដ្ឋឯទៀត (គ្មានអ្នកណាអាចធ្វើទុក្ខបុកម្នេញ ឬជិះជាន់សង្កត់សង្កិនអ្នកទាំងនេះបានទេ) ។

គេនឹងត្រូវដោះលែងពួកអ្នកទោសសង្គ្រាម និងអ្នកទោសនយោបាយទាំងអស់ ។

អង្គការសហប្រជាជាតិ UNTAC នឹងមានការត្រួតត្រាមើលខាងកិច្ចប្រតិបត្តិច្បាប់, ទទួលពាក្យបណ្តឹងពីពលរដ្ឋខ្មែរអំពីការរំលោភសិទ្ធិ, អង្កេតរកហេតុផលនៃការរំលោភ ហើយរកវិធីដោះស្រាយឲ្យសមរម្យ ។

សន្ធិសញ្ញាសន្តិភាពចែងថា គោលដៅជាចំបងក្នុងការកសាងប្រទេសខ្មែរសាឡើងវិញ គឺអប់រំពលរដ្ឋខ្មែរគ្រប់រូបឲ្យចេះលើកស្ទួយទ្រទ្រង់ និងគោរពសិទ្ធិមនុស្ស ហើយនិងមូលដ្ឋាននៃសេរីភាពជាទូទៅ ។

អ្នកដឹកនាំបក្សនយោបាយខ្មែរសន្យាថា នឹងបញ្ចូលបញ្ញត្តិសិទ្ធិមនុស្សសំខាន់ៗជាច្រើន ទៅក្នុងច្បាប់រដ្ឋធម្មនុញ្ញថ្មីរបស់ខ្មែរ ក្រោយពីពេលបោះឆ្នោតហើយ ។

បញ្ញត្តិទាំងនោះគឺ ៖

- សិទ្ធិមានជីវិត
- សិទ្ធិមានសេរីភាពផ្ទាល់ខ្លួន
- សិទ្ធិមានសន្តិសុខ
- សេរីភាពគោចរ
- សេរីភាពខាងសាសនា, ខាងការប្រជុំគ្នា, ខាងការបង្កើតសមាគម (ដោយរួមទាំងការបង្កើតសហជីព និងការបង្កើតបក្សនយោបាយផងដែរ) ។
- ការអនុវត្តន៍ច្បាប់តាមលំនាំត្រឹមត្រូវ ហើយនិងភាពស្មើគ្នានៅចំពោះមុខច្បាប់ ។
- សិទ្ធិការពារកុំឲ្យមានការរឹបអូសទ្រព្យសម្បត្តិតាមតែអំពើចិត្ត និងដោយឥតបង់ថ្លៃសម្បត្តិទាំងនោះ ។
- សិទ្ធិការពារខ្លួនប្រឆាំងនឹងការរើសអើង (ឬប្រកាន់)ពូជកំណើត, សាសន៍, សាសនា ឬភេទ ។
- ក្រសួងតុលាការស្វ័យភាពមួយនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញសំរាប់ការពារសិទ្ធិប្រជាពលរដ្ឋ ។
- ការបោះឆ្នោតជាទូទៅតាមអាណត្តិ ដែលមានចែងយ៉ាងទៀងទាត់, ការបោះឆ្នោតនេះត្រូវធ្វើតាមការទម្លាក់សន្លឹកឆ្នោតមួយម្នាក់ទៅក្នុងប្រអប់ដែលបិទជិត ។
- សិទ្ធិពេញទី និងសិទ្ធិស្មើគ្នា ក្នុងការរៀបចំ ឬចូលរួមក្នុងពិធីបោះឆ្នោត ។

(នៅមានត)